# អង្គការសង្គមស៊ីវិល និងក្រុមអ្នកជំនួញ កើតទុក្ខមិនសុខចិត្តចំពោះរដ្ឋាភិបាល ផ្អាកសកម្មភាពអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

## “យើងទាំងអស់គ្នា គឺសមាគមន៍ផាងត្នោត!”

យើងខ្ញុំទាំងអស់គ្នា ជាតំណាងអង្គការសង្គមស៊ីវិល និងក្រុមអ្នកជំនួញ ដូចមានចុះហត្ថលេខាខាងក្រោម សូមគាំទ្រការអភិវឌ្ឍជាតិដែលប្រកបដោយសមធម៌ ប្រកបដោយការចូលរួម និងដោយនិរន្តរភាព។ យើងខ្ញុំជឿជាក់ថា ការអភិវឌ្ឍជាតិ មិនគួរត្រឹមតែ រួមចំណែកដល់ការរីកចម្រើន ផ្នែកពាណិជ្ជកម្ម និងឧស្សាហកម្មប៉ុណ្ណោះទេ តែគប្បីរួមចំណែកដល់ការរីកចំរើនផ្នែកសុខមាលភាពរបស់ប្រជាពលរដ្ឋទូទៅ។ អង្គការសង្គមស៊ីវិល ទាំងក្នុងស្រុក និងបរទេស ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ តាមរយៈសកម្មភាពឃ្លាំមើលការអភិវឌ្ឍសហគមន៍កាត់បន្ថយភាពក្រីក្រ សកម្មភាពមនុស្សធម៌ ការងារស្រាវជ្រាវ និងការងារតស៊ូមតិ។ នៅក្នុងដំណើរការលើកស្ទួយដល់ការអភិវឌ្ឍប្រកបដោយសមធម៌ យើងក៏មានសិទ្ធិ និងការទទួលខុសត្រូវក្នុងការនិយាយជាចំហរផងដែរអំពីគម្រោងអភិវឌ្ឍដែលមានផលប៉ះពាល់ជាអវិជ្ជមាន។

រយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ វិស័យសង្គមស៊ីវិល បានអភិវឌ្ឍខ្លួនយ៉ាងសកម្មក្នុងប្រទេសកម្ពុជា។ អនាគតនៃវិស័យនេះ អាស្រ័យលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងខាងសមាគម ដូចដែលបានធានា និងមានចែងយ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។

បច្ចុប្បន្ននេះ យើងមើលឃើញថាអនាគតនៃប្រជាធិបតេយ្យកម្ពុជា ស្ថិតនៅលើផ្លូវបំបែក។ សេចក្តីព្រាងច្បាប់លើកទី៣ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល កំពុងតែស្ថិតនៅគណៈរដ្ឋមន្ត្រី ហើយអាចជិតនឹងត្រូវបានអនុម័ត។

នៅថ្ងៃទី២ ខែសីហា ក្រសួងមហាផ្ទៃ បានចេញលិខិតមួយទៅកាន់ សមាគមផាងត្នោត ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អោយ “ផ្អាកសកម្មភាព” រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ដែលមានរយៈពេល ៥ ខែ។ សមាគមផាងត្នោត ធ្វើការជាមួយសហគមក្រីក្រក្នុងទីក្រុង ទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន។ សមាគមនេះ គឺជាសមាជិកមួយនៃបណ្តាញរបស់អង្គការសង្គមស៊ីវិលមួយចំនួន ហើយដែលសមាគមន៍នេះទទួលបាននូវការគោរពជាខ្លាំងផងដែរ។

លិខិតក្រសួងមហាផ្ទៃនេះ មិនបានបញ្ជាក់ពីមូលដ្ឋានច្បាប់សម្រាប់ការផ្អាកនេះទេ។ លិខិតបានត្រឹមតែចោទប្រកាន់សមាគមផាងត្នោតថា មិនបានកែសម្រួលរចនាសម្ព័ន្ធដឹកនាំ និងកែប្រែលក្ខន្តិកៈសមាគម “តាមការណែនាំរបស់ផ្នែកជំនាញ”។ លិខិតនេះ មិនបានផ្តល់នូវសេចក្តីពន្យល់អ្វីបន្ថែមទៀតទេ។ ទោះបីជាយ៉ាងណាក៏ដោយ យើងដឹងថា មូលហេតុពិតប្រាកដនៃការផ្អាកសកម្ម- ភាពសមាគមផាងត្នោត គឺដោយសារតែការធ្វើការងារត្រឹមត្រូវរបស់អង្គការនេះជាមួយសហគមក្រីក្រក្នុងទីក្រុង។

យើងមិនដឹងថា មានបញ្ញត្តិច្បាប់ដែលអនុញ្ញាតអោយមានការផ្អាកសកម្មភាពបែបនេះទេ ហើយការអោយផ្អាកសកម្មភាពអង្គការរយៈពេលដ៏យូររហូតដល់ទៅ៥ខែ ក៏ហាក់ដូចជាចំណាត់ការតាមទំនើងចិត្តទាំងស្រុង។ ក្រសួងមហាផ្ទៃ មិនឆ្លើយតបចំពោះកិច្ចខិតខំស្វែងរកការបញ្ជាក់ឡើងវិញលើលិខិតនេះឡើយ។

យើងខ្ញុំ កើតទុក្ខមិនសុខចិត្តយ៉ាងខ្លាំង ចំពោះទង្វើផ្អាកសកម្មភាពសមាគមធាងត្នោតនេះ។ ការផ្អាកសកម្មភាពសមាគមធាងត្នោត គឺពិតជាទង្វើតាមទំនើងចិត្ត ហើយជាការរំលោភលើសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ គឺសេរីភាពខាងការបញ្ចេញមតិ និងខាងសមាគម និងក៏ជាការបង្ក្រាបលើអ្នកការពារសិទ្ធិមនុស្សផងដែរ។ យើងខ្ញុំទាមទារអោយ មានការកែប្រែការសម្រេចនេះអោយទៅរកសភាពដើមវិញជាបន្ទាន់។ យើងខ្ញុំគិតថា ទង្វើបំបាត់សំលេង សមាគមធាងត្នោត គឺជាទង្វើគាបសង្កត់លើសង្គមស៊ីវិលយើងខ្ញុំទាំងអស់គ្នា។ ការប្រើប្រាស់បច្ចេកទេសរដ្ឋបាលបែបស្រពេចស្រពិល ដើម្បីផ្អាកសកម្មភាពអង្គការមួយនេះ គឺជាសញ្ញា ប្រកាសអាសន្នយ៉ាងច្បាស់ក្រឡែតមួយ ដែលរដ្ឋាភិបាលកម្ពុជាមានបំណងប្រើប្រាស់ច្បាប់ ស្តីពីសមាគមន និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរារាំងសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលធ្វើលើការតស៊ូមតិដើម្បីសិទ្ធិរបស់ក្រុមប្រជាពលរដ្ឋដែលគេមិនគិតគូរដល់នៅក្នុងសង្គមកម្ពុជា។

ការងាររបស់សមាគមធាងត្នោត ដែលធ្វើការងារជាមួយសហគមន៍ក្រីក្របំផុតក្នុងប្រទេសកម្ពុជា គួរតែត្រូវបានលើកសរសើរ មិនមែនធ្វើអោយពួកគេបាត់សំលេងនោះទេ។ ការសិក្សាស្រាវជ្រាវ ដែលមានលក្ខណៈឯករាជ្យ និងប្រកបដោយគុណភាពលើផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍ ដែលសមាគមធាងត្នោតបានធ្វើ គួរតែបានចាត់ទុកថា ជាជំនួយមួយសម្រាប់ទាំងគម្រោងអភិវឌ្ឍបច្ចុប្បន្ន និងអនាគតដើម្បីបម្រើជាប្រយោជន៍យ៉ាង ប្រសើរដល់ប្រជាពលរដ្ឋកម្ពុជា។ យើងខ្ញុំសូមជំរុញដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ សូមអានរបាយការណ៍ថ្មីៗបំផុតរបស់សមាគមធាងត្នោត ដែលមាននៅលើគេហទំព័ររបស់សមាគមនេះ ហើយ វិនិច្ឆ័យដោយខ្លួនឯងលើគុណតម្លៃការងាររបស់សមាគមធាងត្នោត។

របាយការណ៍មាននៅលើគេហទំព័រ៖
http://teangtnaut.org/PDF/Rehabilitation%20of%20Cambodias%20Railways_STT%20July%202011.pdf

ខាងក្រោមនេះជាឈ្មោះអង្គការសង្គមស៊ីវិល និងក្រុមអ្នកជំនួញ ដែលគាំទ្រសេចក្តីថ្លែងការនេះ ខែសីហា ឆ្នាំ ២០១១៖

1. ActionAid Cambodia
2. Amnesty International (AI)
3. Asia Indigenous Peoples Pact (AIPP)
4. Asia Monitor Resource Centre Hong Kong (AMRC)
5. Bridges Across Borders Cambodia (BABC)
6. Building Community Voices (BCV)
7. Calvin Presbyterian Church
8. Cambodian Center for Human Rights (CCHR)
9. Cambodian Center for Independent Media (CCIM)
10. Cambodian Committee for Women (CAMBOW)
11. Cambodian Confederation of Unions (CCU)
12. Cambodian Food and Service Workers Federation (CFSWF)

13. Cambodian Human Rights Action Committee (CHRAC)
14. Cambodian Human Rights and Development Association (ADHOC)
15. Cambodian Independent Teachers Association (CITA)
16. Cambodian Labour Confederation (CLC)
17. Cambodian League for the Promotion and Defense of Human Rights (LICADHO)
18. Cambodian NGO Committee on CEDAW (NGO-CEDAW)
19. Cambodian Watchdog Council (CWC)
20. Cambodia Women's Crisis Center (CWCC)
21. Cambodian Women's Network for Development (AMARA)
22. Cambodian Youth Network (CYN)
23. Center on Housing Rights and Evictions (COHRE)
24. Chab Dai Coalition Cambodia
25. Christian Aid (CA)
26. Christliche Initiative Romero (CIR)
27. Christians for Social Justice (CSJ)
28. Christian Reformed World Relief Committee (CRWRC)
29. Civic Alliance for Social Accountability in Cambodia (CASA)
30. Civil Rights Defenders
31. Civil Servant Independent Association (CICA)
32. Clean Clothes Campaign Denmark (CCCDK)
33. Clean Clothes Campaign Netherlands (CCCNL)
34. Coalition of Cambodian Apparel Workers Democratic Union (C.CAWDU)
35. Coalition of Cambodian Farmer Community (CCFC)
36. Collaborative Studio
37. Committee for Free and Fair Elections in Cambodia (COMFREL)
38. Community Capacities for Development (CCD)
39. Community Economic Development (CED)
40. Community Legal Education Center (CLEC)
41. Community Organization for People's Action Thailand (COPA)
42. Community Organization in Asia (LOCOA)
43. Community Peacebuilding Network (CPN)
44. Concern Worldwide Cambodia
45. Cooperation Committee for Cambodia (CCC)
46. Danchurch Aid (DCA)
47. Democratic Dimension Ukraine
48. Development and Partnership in Action (DPA)
49. Development & Peace (D & P)
50. Diakonia
51. East-West Management Institute Program on Rights and Justice (EWMI-PRAJ)
52. Empowering Youth in Cambodia (EYC)
53. Evangelischer Entwicklungsdienst (EED)
54. Education International (EI-IE)
55. Epic Arts Cambodia
56. Farmers Association for Peace and Development (FAPD)
57. Forum-Asia (FA)
58. Forum Syd (FS)
59. Four Regions Slum Network Thailand (FRSN)
60. Foursquare Children of Promise (FCOP)
61. Freedom House (FH)
62. Front Line Defenders
63. Gender And Development For Cambodia (GADC)

64. Global Witness (GW)
65. Hard Places Community (HPC)
66. Heinrich Boell Stiftung (HBS)
67. Housing Rights Task Force (HRTF)
68. HRD Apparels
69. Human Rights Watch (HRW)
70. Human Settlement Foundation Thailand (HSF)
71. Imago Dei Church
72. Indigenous Community Support Organization (ICSO)
73. Indigenous Rights Active Member (IRAM)
74. Independent Democracy of Informal Economy Association (IDEA)
75. INKOTA-netzwerk (INKOTA)
76. KEPA-Service Centre for Development Cooperation
77. Khmer Arts
78. Khmer Youth Association (KYA)
79. KOMITU Working Group Finland
80. Labour Behind the Label (LBL)
81. Legal Support for Children and Women (LSCW)
82. LICADHO Canada (LC)
83. Life With Dignity
84. Living River Siam Thailand
85. Love146
86. Maryknoll
87. Mekong Watch
88. MISEREOR
89. My Village (MVi)
90. National Democratic Institute (NDI)
91. National Forum for the Urban Poor (NFUP)
92. NGO Coalition to Address Trafficking & Sexual Exploitation of Children in Cambodia (COSECAM)
93. NGO Committee on the Rights of the Child (NGOCRC)
94. NGO Education Partnership (NEP)
95. Norwegian People's Aid (NPA)
96. Observatory for the Protection of Human Rights Defenders (FIDH-OMCT)
97. One-2-One Cambodia (one-2-One)
98. Operation Day's Work Finland (ODW)
99. Oxfam
100. Pari Project
101. People's Action for Change (PAC)
102. People's Organisation of Wadala for Equality & Rights (POWER)
103. People's Responsible Organisation of United Dharavi (PROUD)
104. Persatuan Sahabat Wanita Selangor (PSWS)
105. Planet Wheeler Foundation
106. Ponlok Khmer
107. Servants Cambodia
108. SILAKA
109. Social Action for Change (SAC)
110. Society of Community Organizers in India (SOCO)
111. Southeast Asia Coordinator of Asia Floor Wage Alliance
112. Sor Sor Troung (SST)
113. Star Kampuchea (SK)

114. Shelter for the Poor
115. Students & Scholars Against Corporate Misbehavior (SACOM)
116. Teachers, City in Crisis-Course, Finland
117. Thai Labour Campaign (TLC)
118. The Change To Win Labor Federation (CtW)
119. The Messenger Band (MB)
120. The NGO Forum on Cambodia (NGO FORUM)
121. Trocaire
122. Ukumbi
123. Urban Poor Women Development (UPWD)
124. Volunteer for Sustainable Development (VSD)
125. Welthungerhilfe
126. WITNESS
127. Women for Prosperity (WFP)
128. Women League Struggle for Housing Rights
129. Women's Media Center of Cambodia (WMC)
130. World Education Cambodia (WE-C)